# Artists Talk

## ម៉ាលីន ដាណែត និងធានលី បកស្រាយពីបទពិសោធន៍ជីវិត ក្នុងនាមជាសិល្បករចក្ខុទស្សន៍ដែលប្រកបដោយទេពកោសល្យខ្ពស់

Artists Talk ត្រូវបានសហការរៀបចំដោយអង្គការសិល្បៈខ្មែរអមតៈ ស-សបាសាក់ និងចូលរួមផ្តល់ទីកន្លែងដោយ វិចិត្រសាលសាមគ្គីដែលមានទីតាំងស្ថិតនៅក្នុងទីរួមខេត្តបាត់ដំបង។ សូមបញ្ជាក់ផងដែរថាកម្មវិធីនេះរៀបចំឡើងក្នុងគោលបំណងចែករំលែកបទពិសោធន៍ក្នុងគំនិតច្នៃប្រឌិតរបស់កំពូលសិល្បករចក្ខុទស្សន៍ទាំង៣រូប ដែលរួមមាន៖ លោក ធានលី អ្នកនាងម៉ាលីន និងកញ្ញាដាណែត។ ក្នុងចំណោមសិល្បករចំនួន៥០នាក់ ដែលបានដាក់ពាក្យ ទៅ Cambodia Living Art ដើម្បីបានចូលរួមការតាំងបង្ហាញស្នាដៃរបស់ខ្លួននៅ Vermont Studio Center មានតែសិល្បករចក្ខុទស្សន៍ចំនួន៣រូបតែប៉ុណ្ណោះ ដែលត្រូវបានជ្រើសរើសទៅចូលរួមក្នុងកម្មវិធីនោះ ហើយក៏ជាជំនាន់ទី១ ដែល Vermont Studio Center បានធ្វើការសហការជាមួយ Cambodia Living Art។ ដើម្បីជ្រាបកាន់តែច្បាស់ ទស្សនាវដ្តី សូវរិន បានចុះទៅធ្វើបទសម្ភាសន៍ជាមួយសិល្បករទាំងបីរូបដោយផ្ទាល់នៅខេត្តបាត់ដំបង ដែលមានខ្លឹមសារដូចខាងក្រោម។


លោក ធានលី
កញ្ញា អេង វិទ្ធចន្ទ័ដាណែត
អ្នកនាង យឹម ម៉ាលីន

កញ្ញា អេង រិទ្ធចន្ទ័ដាណែត អាយុ២៣ឆ្នាំ ជាសិល្បករចក្ខុទស្សន៍ដែលមានជំនាញផ្នែក៖ Photography, Visual Art (Structure Installation) និង Documentary Film ។ វាគឺជាលើកទី១ ក្នុងឆាកជីវិតរបស់ ដាណែត ដែលមានឱកាសធ្វើដំណើរទៅចូលរួមកម្មវិធីតាំងបង្ហាញស្នាដៃនៅសហរដ្ឋអាមេរិកជាមួយសិល្បករបរទេសជាច្រើនរូប។ "វាបានផ្លាស់ប្តូរខ្ញុំច្រើនមែនទែនជាមួយបទពិសោធន៍ការងារជាច្រើននៅទីនោះ។ បទពិសោធន៍ទី១ដែលខ្ញុំទទួលបាននោះគឺការផ្លាស់ប្តូរវប្បធម៌គ្នាទៅវិញទៅមក ទី២ខ្ញុំបានរៀនអំពីការទំនាក់ទំនងគ្នាគឺខ្ញុំបានចាប់ផ្តើមការអនុវត្តភាសា ហើយខ្ញុំក៏បានសិក្សាអំពីវត្ថុធាតុដើមក្នុងការផលិតនិងទិកនិកក្នុងការធ្វើការងារសិល្បៈចក្ខុទស្សន៍នៅសហរដ្ឋអាមេរិក ព្រមទាំងសិក្សាបន្ថែម លើអ្វីដែលគេមានហើយនៅក្នុងប្រទេសយើងមិនមាន" ដាណែតនិយាយ។ រយៈពេល៥សប្តាហ៍ដែល ដាណែត បានធ្វើនិវាសនដ្ឋាន (Residency) នៅ Vermont studio Center & Triangle Art Studio នាងបានពាំនាំយកទៅជាមួយនូវវត្ថុធាតុដើមពីប្រទេសកម្ពុជាគឺសូត្រខ្មែរ។ មុននឹងចាកចេញពីប្រទេសកម្ពុជាទៅកាន់សហរដ្ឋអាមេរិកនាងមិនបានរៀបចំគម្រោងក្នុងការធ្វើការងារសិល្បៈ(Work Art) របស់នាងជាមុននោះទេ នៅពេលដែលទៅដល់ Vermont Studio Center នាងបានក្រឡេកឃើញពីវត្ថុធាតុដើមដែលមាននៅទីនោះរួមជាមួយបរិយាកាសសិល្បៈដែលនៅជុំវិញខ្លួន ក៏បានធ្វើឲ្យនាងបង្កើតចេញ ជាគំនិតមួយផុសឡើងមកតែម្តង។ នៅក្នុងនោះផងដែរ Vermont Studio Center បានរៀបចំជាស្ទូឌីយោផ្ទាល់ខ្លួនសម្រាប់សិល្បករម្នាក់ៗដើម្បីធ្វើការតាំងបង្ហាញស្នាដៃសិល្បៈរបស់ខ្លួន ដោយឡែកនៅ Triangle Art Studio (ក្រុងញូវយ៉ក) គេបានរៀបចំស្ទូឌីយោឲ្យតែមួយទេដើម្បីឲ្យសិល្បករបានតាំងបង្ហាញស្នាដៃរួមគ្នា។ នៅក្នុងឱកាសតាំង បង្ហាញស្នាដៃសិល្បៈនៅ Vermont Studio ដាណែត បានសម្លឹងឃើញពីការអភិវឌ្ឍន៍របស់ប្រទេសគេជាមួយប្រទេសកម្ពុជាយើងមានភាពខុសប្លែកគ្នាខ្លាំងមែនទែន "នៅពេលនោះខ្ញុំក៏នឹកឃើញការងារ សូនរូបក្បាលមនុស្ស កំណាត់ឆ្អឹង ដែលធ្វើឡើងពីដីឥដ្ឋ ដើម្បីធ្វើការឆ្លុះបញ្ចាំងពីការអភិវឌ្ឍន៍រវាងស្រុកខ្មែរដែលកំពុងតែមានការអភិវឌ្ឍន៍ ប៉ុន្តែបានជួបប្រទះបញ្ហាជាច្រើនជាមួយប្រជាជនដូចជា ការផ្តល់នូវសំណងមិនសមរម្យឬមានបញ្ហាផ្សេងៗទៀតដែលពាក់ព័ន្ធនឹងប្រជាជន" ដាណែតនិយាយ។ ដោយឡែករូបភាពមួយទៀតដែល ដាណែត បានធ្វើនិងដាក់តាំងបង្ហាញនោះគឺក្បាលរបស់មនុស្សប្រុសម្នាក់ដែលមើលទៅគាត់ជាប្រធានក្រុមហ៊ុនឬ ជាអ្នកដឹកនាំមួយរូប ដោយមានពាក់វ៉ែនតាពណ៌ខ្មៅក្នុងអត្ថន័យចង់បញ្ជាក់ប្រាប់ថា ក្នុងការដែលគាត់ដាក់ទុនធ្វើអ្វីមួយ ឬអ្វីដែលគាត់កំពុងតែអភិវឌ្ឍន៍ ប៉ុន្តែគាត់មិនបានក្រឡេកមើលការធ្វើរបស់គាត់វាត្រូវឬក៏ខុសនោះទេ ថាតើអភិវឌ្ឍន៍ដោយស្នាមញញឹមរបស់ប្រជាជន ឬក៏អភិវឌ្ឍន៍លើទឹកភ្នែករបស់ប្រជាជន! ចំពោះស្នាដៃដែល ដាណែត បានដាក់តាំងបង្ហាញនៅ Triangle Art Studio នាងបានធ្វើជារូបផែនទីរបស់ Vermont studio និងរូបផែនទីរបស់ប្រទេសកម្ពុជាដែលធ្វើចេញពីសន្លឹកមាសដើម្បីជាការដាក់តាំងបង្ហាញស្នាដៃរួមគ្នា។

ដោយឡែក អ្នកនាង យឹម ម៉ាលីន ដែលជាសិល្បករចក្ខុទស្សន៍មួយរូបពោរពេញដោយគំនិតច្នៃប្រឌិត ហើយបានឈរលើវិថីសិល្បៈនេះតាំងពីអាយុ១៨ឆ្នាំបានឲ្យដឹងថា "នៅពេលដែលខ្ញុំបានទៅដល់ Vermont Studio Center ធ្វើឲ្យខ្ញុំមានកម្លាំងចិត្តខ្លាំងមែនទែនក្នុងការបំពេញការងារ។ រំលឹកកាលពីពេលដែលខ្ញុំបានទៅធ្វើ Residency នៅ Vermont Studio ខ្ញុំអត់បានគិតឬមានគំនិតថានឹងធ្វើអ្វីមួយនោះទេ ឬក៏យកជាសម្ភារអ្វីទៅជាមួយដើម្បីទៅធ្វើការងារនោះទេ គឺខ្ញុំទុកឲ្យពេលវេលាជាអ្នកសម្រេច។ ខ្ញុំចង់ឲ្យការងាររបស់ខ្ញុំកើតឡើងជាយថាហេតុ ចុងក្រោយតើវានឹងមានអ្វីកើតឡើងចំពោះខ្ញុំ! ការងារដែលខ្ញុំចាប់ផ្តើមនៅពេលនោះគឺខ្ញុំចាប់ផ្តើមយកធ្យូងគូរនៅលើក្រដាសធំវែងដែលមានប្រវែង១៤ម៉ែត្រ ហើយខ្ញុំក៏ចេះតែគូរទៅៗ រហូតដល់អស់ក្រដាស២ទៅ៣ដុំ ប៉ុន្តែខ្ញុំមិនទាន់មានគំនិតអ្វីទាំងអស់គ្រាន់តែដឹងថាពេលនោះខ្ញុំចង់ធ្វើអ្វីមួយដែលទាក់ទងនឹងដើមឈើរហូតខ្ញុំផុសគំនិតធ្វើដើមឈើចេញជារូបស្រួចៗវែងៗនេះឡើង។ ការងារនេះពីដំបូងឡើយខ្ញុំគិតថាគ្រាន់តែតម្លើងវាហើយយកទៅតាំងក្នុងស្ទូឌីយោនៅ Vermont គឺរួចរាល់។ ប៉ុន្តែវាមិនដូចការរំពឹងគិតរបស់ខ្ញុំនោះទេ គំនិតរបស់ខ្ញុំបានផុសឡើងជាមួយនឹងការធ្វើយ៉ាងណាដើម្បីអោយដើមឈើទាំងអស់របស់ខ្ញុំមានជីវិតថ្មីជាមួយនឹងបរិយាកាសខាងក្រៅស្ទូឌីយោវិញម្តង។ ហើយខ្ញុំចាប់ផ្តើមយកដើមឈើនោះយកទៅដោតនៅកន្លែងផ្សេងៗជុំវិញស្ទូឌីយោរបស់ខ្ញុំនៅ Vermont រួចហើយខ្ញុំបានដាក់តម្លើងចោលនៅក្រោមកម្តៅថ្ងៃក្រោមសន្សើមចោលមួយយប់។ ដល់ពេលព្រលឹមឡើងម៉ោង៦ព្រឹក ខ្ញុំក្រោកទៅមើលការងាររបស់ខ្ញុំ ក៏ឃើញដើមឈើខ្លះដួលខ្លះត្រូវបានសត្វចាប់ទាញហែក ធ្វើឲ្យខ្ញុំមានអារម្មណ៍ទំនាក់ទំនង

## “សិល្បករចក្ខុទស្សន៍ទាំងបីរូបនឹងចូលរួមចែករំលែកបទពិសោធន៍ជាមួយ សហគមន៍សិល្បករបន្ទាប់ពីបានចូលរួមក្នុងការបង្ហាញស្នាដៃនៅ Vermont Studio Center & Triangle Art Studio ”

ខ្លាំងជាមួយនឹងដើមឈើទាំងអស់នោះ។ អ្វីទាំងនេះគឺខ្ញុំចង់សរបញ្ជាក់នឹងបង្ហាញអំពីបញ្ហារបស់មនុស្សយើងសព្វថ្ងៃចុងបញ្ចប់គឺដេកនៅមួយកន្លែង" អ្នកនាង ម៉ាលីន បានបង្ហាញប្រាប់។ ដោយឡែកនៅ Triangle Art Studio អ្នកនាងម៉ាលីន បានទៅទស្សនាកន្លែងលក់វត្ថុនិងសម្ភារសិល្បៈហើយក៏បានចាប់អារម្មណ៍រូបរបាំងមុខស្វា។ បន្ទាប់មកអ្នកនាង ម៉ាលីន ក៏បានគ្រងជាមួយសម្លៀកបំពាក់ពណ៌ខ្មៅហើយពាក់របាំងមុខស្វានោះ ហើយក៏បានឲ្យអ្នកដែលបានចូលរួមការងារទាំងអស់គ្នានៅទីនោះ យកខ្សែមកចងរុំខ្លួនគាត់។ តាមរយៈអ្វីដែលអ្នកនាង ម៉ាលីន បានធ្វើបង្ហាញនេះគាត់ចង់បង្ហាញប្រាប់ពីអត្ថន័យថា "នៅពេលមនុស្សម្នាក់ៗ មានបញ្ហាអ្វីមួយដោះស្រាយមិនចេញ ពួកគាត់តែងតែ ទៅរកគ្រូហោរាទាយដើម្បីស្រាយចម្ងល់ក្នុងចិត្ត។ ចំពោះខ្សែពណ៌ទឹកក្រូច វាគ្រាន់តែទាក់ទងជាមួយនឹងជំនឿរបស់មនុស្សម្នាក់ៗ ដោយឡែកខ្សែពណ៌សវិញគឺចង់បង្ហាញអំពីការចងការពារសម្បត្តិធម្មជាតិដែលមាន តើសត្វទាំងអស់ហ្នឹងអាចទៅរស់នៅទីកន្លែងណាបានប្រសិនជាអត់មានព្រៃឈើ"។ ការសម្តែងនេះទៀតសោតន៍ អ្នកនាង ម៉ាលីន បានធ្វើជាវីដេអូដែលមានរយៈពេល១១នាទី ព្រមជាមួយខ្លឹមសារដ៏មានអត្ថន័យទាក់ទងនឹងព្រៃឈើ ។ សូមបញ្ជាក់ផងដែរថាការសម្តែងនេះអ្នកនាង ម៉ាលីន បានធ្វើម្តងទៀតនៅខេត្តបាត់ដំបង។

ខុសប្លែកពីសិល្បករចក្ខុទស្សន៍ទាំងពីរខាងលើ លោក ធានលី បានឲ្យដឹងថា "ខ្ញុំបានធ្វើការគ្រោងទុករយៈពេលយូរឆ្នាំមកហើយ ខ្ញុំចង់ទៅរៀនអំពីបច្ចេកទេស តែសម្រាប់ការចេញទៅលើកនេះខ្ញុំមិនត្រឹមតែបានរៀនពីបច្ចេកទេស នោះទេគឺខ្ញុំបានរៀនអំពីគំនិតថ្មីៗដែលមិនមានការរៀបចំទុកជាមុន។ ហើយទន្ទឹមនឹងនោះខ្ញុំបានគូររូបគំនូរដែលមានចំណាំងផ្លាតយកទៅធ្វើការតាំងបង្ហាញនៅ Vermont Studio Center"។ ដោយឡែកពេលដែលលោកទៅដល់ ទើបលោកចាប់ផ្តើមគូរគំនូរ បានចំនួន២ផ្ទាំង។ បន្ទាប់ពីចូលរួមជាមួយការតាំងបង្ហាញស្នាដៃនៅ Vermont Studio និងនៅ Triangle Art Studio សិល្បករចក្ខុទស្សន៍ ធានលី បានពាំនាំបទពិសោធន៍របស់លោកថា "ពេលបានទៅដល់សហរដ្ឋអាមេរិកគឺខ្ញុំរៀនបានច្រើនមែនទែនទាំងផ្នែកបច្ចេកទេស ទាំងគំនិតនិងចំណេះដឹងទូទៅ។ ការរៀនស្គាល់ពីបច្ចេកទេសគឺខ្ញុំបានសម្លឹងឃើញ នៅស្រុកគេបានរក្សាទុកនៅស្នាដៃប្រវត្តិសាស្ត្រនិងស្នាដៃនាពេលបច្ចុប្បន្នព្រមជាមួយការបង្កើតនូវរបត់គំនិតថ្មីៗ វាទូលំទូលាយមែនទែន។ ហើយខ្ញុំគិតថាថ្ងៃនេះជាថ្ងៃមួយដ៏មានសារសំខាន់ ហើយវាជាឱកាសល្អមែនទែនដែលខាង ស-សបាសាក់ បានផ្តួចផ្តើមគំនិតបង្កើតជាសិក្ខាសាលាដែលធ្វើឲ្យសិល្បករចក្ខុទស្សន៍មានពេលវេលាជួបជុំគ្នានឹងផ្លោះប្តូរបទពិសោធន៍រវាងគ្នាទៅវិញទៅមក"។ ជាចុងក្រោយលោក ធានលី ក៏បានធ្វើការស្នើសុំក៏ដូចជាការជំរុញទឹកចិត្តយុវជនជំនាន់ក្រោយអោយមានមនសិកាដោយខ្លួនឯង មិនត្រូវពឹងលើសាលាទាំងស្រុងនោះទេ ជួនកាលសាលាជួយយើងអស់ពីសមត្ថភាពហើយដោយឡែកខ្លួនយើងក៏ត្រូវមានទស្សនៈខ្លួនឯងដែរ ព្រោះដើម្បីឲ្យយើងគោរពនូវទេពកោសល្យដែលខ្លួនយើងមាន ហើយមិនត្រូវបោះបង់ពាក់កណ្តាលទី និងកុំផ្តេកផ្តួលទៅតាមសង្គមនាពេលបច្ចុប្បន្ន៕

*by Makara*

SOVRIN Preview (P. 26 - 29)

# WHAT'S UP FOR 2016?

## Are you ready for 2016? What is the next change of the fashion world? How about us here in Cambodia?

The way people live changes from generation to another due to these factors: Culture, religious beliefs, geography, and influence from other countries. They make people's fashion experience more remarkable. Human's style determine where they are from. In short, it shows individual's identity about how they live and dress up. It is considered as part of living for humankind. We can know them from their dressing style, so outfitting becomes an important part and is widely defined as "Trend" which details the creativity of arts, identity, nationalism, and civilization until today.

Looking at the world of fashion, there is so much to take in. However, there is one way that people follow dressing up themselves. Fashion weeks like Paris Fashion Week, Milan Fashion Week, New York Fashion Week, has made the world of fashion more incredible. The gracefulness of the fashion is a core factor that Chanel makes everyone amazed of. The brand with its own style and creativity for this spring and summer 2016 has come up with a concept of Airport set up for their runway show. Everyone has turned into passengers and crews of Chanel Airlines. Colorful classic tweedy skirt & suit blazer are their significance. The trend is inspired lives around us all. For Dolce & Gabbana Spring Summer 2016, models walked on the stage with a shopping theme and paused for a selfie with very colorful costumes. This fashion week is call Italia is Love, which explains the way of people leisure life. For spring and summer 2016, Christian Dior brought black and white outfits to the stage which perfectly fits the stage with a blue delphiniums garden. Jacket with a mini skirt, sheer crop top as well as lace blouse are the most elegant pieces. As mentioned above, those big brands try to find something attractive and connect the world with cultures and globalization. This makes the world of fashion even more alive.

For fashion in Cambodia gradually seems to grow remarkably. Even though we don't have the specific tendency, we can understand that our society is likely to get something new. Fashion event, profession training school, and acceptance of something new are the signs of our forward trend. As we know, our fashion is influenced by neighboring countries. We don't have our own dressing styles yet. Nevertheless, our fashion has become recognizable. Our next generation has made this happen by instilling the recent fashion and favor our local people as well. Our young fashion designers in Cambodia are active and besides the more civilized people are the smarter their life is.

For our everyday living, we cannot live without nature; likewise, the fashion is also connected with nature. As a matter of fact, world's fashion designer Alexander McQueen has invented his brand and gets famous worldwide. His work is considered valuable and his idea of fashion is always connected to the world. Mr. Nat Soknan, a local fashion designer showed his work at big fashion events both locally and internationally. His sense of fashion is related to nature and makes everyone feel fresh. He creates his fashion dresses with the ideas of sea, lake and trees, etc. For this 2016, he will turn a female model into a princess of nature with his incredible idea. For those women who have a hard time finding a proper dress to wear at a party, Khun Kimsour, a modern fashion designer will bring the different and beautiful collection for this upcoming New Year. The lace and sheer trend seem to turn us back to the 70s, and that is the idea of a fashion designer Juli Handaynai. She added, "Kids these days especially those living in Phnom Penh must know pretty well about fashion and they dress the way they like to show their experience in fashion. There are so many to prepare for her future plan, and nowadays she runs a shop under her name. The gifted and young fashion designer Hung Chin is just back from exchanging experience at ASEAN Youth under a fashion topic and business in Malaysia. With a culture as the core, his design is unique and awesome. Even though he is young, his vision with determination is admirable. With hardworking and searching and strengthening ourselves are the goals towards success, this is what a fashion designer Soknan and Kimsour mentioned. Bring out what is new to everyone and use your creativity, said Mr. Chin. For Juli she said, be smart with fashion and never let yourself be a victim of fashion. The opinions and fashion vision as a global region are the best experiences, especially we can get new ideas from those skilled fashion designers to our next generation. This is a very important message for all of us. The ideas of universal fashion and local one makes this happen independently. We hope to see our Cambodian fashion as our own in the future like the ones on the stones from our ancestors. This shows our own style from each generation diligently and marvelously. Therefore, we hope our generation can make this happen for the next generation to witness. ■

SOVRIN Talk (P. 30 - 33)

# ARTISTS TALK

## Three Cambodian visual artists, Maline, Theanly & Daneth have shared their experience of an exhibition journey at the United State.

Artist's Talk is organized by Cambodia Living Arts and Sa Sa Bassac, and held at Sammaki Gallery Hall located in Battambang Province. This program is hosted in the purposes of sharing the creative experience of the three visual artists: Mr. Theanly, Mrs. Maline, and Miss. Daneth. Of all 50 artists applying for Cambodia Living Arts to show their works at Vermont Studio Center, only 3 artists are selected to join this program. It also marks the first project that Vermont Studio Center cooperated with Cambodia Living Arts. To be precise, SOVRIN went for an interview with the three in Battambang Province and the information is as follows.

Miss Eng Rithchandaneth aged 23 is a visual artist specialized in Photography, Documentary Film and Visual Art (Structure Installation). That was the first time in her life to have a chance joining Exhibition in the United States with other artists. "It changes me so much while experiencing over there. Culture exchange is my first experience and follows by language practicing and learning about raw materials and techniques in working with visual arts in the States. I catch up learning about the new thing that do not have in our country." said Daneth. During a five-week stay at Vermont Studio Center & Triangle Art Studio, she also brought with her some raw materials from Cambodia and it was Khmer Silk. Before leaving Cambodia, she didn't plan anything for her work art. When she arrived at Vermont Studio Center, she looked at raw materials around and immediately popped up an idea. In the meantime, Vermont Studio Center set up an individual studio for each artist to show their work. At Triangle Art Studio (New York City), only one studio is set up for the exhibition. Artists had to share the space to show their artwork. At the exhibition at Vermont Studio, Daneth witnessed the complete difference of the development between Cambodia and USA. "At the same time, it reminded me that skull and bone sculpture made from clay will show this issue - The hard life of people with unfair payment or else about people's living condition," Daneth said. At the exhibition there is another work on the wall - a man face wearing a pair of black sunglasses looks like a boss or a leader that means to say once he doing investing or planning he is doing by hook or by crook. He does not care whether it is right or wrong; it makes people smile or cry. At Triangle Art Studio, Daneth showed a map of Vermont Studio and a map of Cambodia made of gold flakes.

For Mrs. Yim Maline, a visual artist full of creativity and involved herself in this industry since she was 14 years old said, "When I arrived Vermont Studio Center, I got so much inspired to complete my work. In memory the time I resided at Vermont Studio, I completely had no idea of what to do or bring any materials along with me. I allowed time to decide. I wanted my task to appear miracle. What happens to me at last? I started drawing with charcoal on a long and wide paper length 14 meters. I just sketched and sketched until I finished a few rolls of paper. Yet nothing came up to mind. I just wanted to do something about a tree until I came up with making the pointed trees using those charcoal painted papers. At first I just thought I would set it up and place at Vermont studio. But it didn't go my way. My concept wants to make my trees be alive with the outer atmosphere at the studio. Then I pinned those trees around the studio and I left them under the sun and dew for a night. At 6 a.m. next day, I got up to check my work and saw some part falling down and some area was torn by the birds. It made me feel inspired and connected to those trees. This explains the problems of us humans that finally we fall down in one place," Mrs. Maline revealed. At Triangle Art Studio, Mrs. Maline paid a visit to Art Shop and interested in a Monkey Mask. After that, she put on a black outfit and wore the mask. And it made her crew tie her with a rope. Through what she showed, Mrs. Maline wanted to give a message that, "Once a person is in trouble and he or she cannot solve it, they always go to a fortune teller to figure out what is on their mind. For the orange strings, it is related to individual belief. For the white ones will represent the conservative of nature. How can those animals live without trees? As a matter of fact, Mrs. Maline made a video lasting 11 minutes with a meaningful message regarding trees. Apparently, her show was once played in Battambang.

Different from the two artists above, Mr. Thean Ly stated that "I planned it a year before. I wanted to learn the technique. Surprisingly with this trip, it's not only the technique but also new ideas that I never expected. Meanwhile, I also painted the reflection drawing and displayed at Vermont Studio Center." When he arrived, he started to draw two paintings. After displaying his work at Vermont Studio and Triangle Art Studio, this visual artist, Thean Ly brought back his experience, "When I arrived the USA, I learned so much both technique and general knowledge. For the technique, America preserves their historical and present works with widely new innovations. Then I think today is such a special day and a golden opportunity for Sa Sa Bassac initiated this workshop. This makes our visual artists have a chance to meet with one another to exchange experiences. Lastly, Mr. Thean Ly requests all youths to have their consciousness rather than depend on your school entirely. Sometimes school tries so hard to help us already but you need your own vision to respect your own talent. You should not give up in the middle of nowhere when you do not get distracted by today's society. ■